ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សកម្មភាពការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆ្នាំ២០១៧ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅឆ្នាំ២០១៧នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានខិតខំបំពេញភារកិច្ចរបស់ខ្លួនយ៉ាងសកម្មក្នុងការបង្កើនផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ដើម្បីរួមចំណែកអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល នីតិកាលទី៥នៃរដ្ឋសភា។ ជាពិសេសការខិតខំបង្វែរទិសដៅនៃការអភិវឌ្ឍតាមបែបវិបុលកម្មឆ្ពោះទៅកាន់ការអភិវឌ្ឍតាមបែបប្រពលវប្បកម្មតាមរយៈការធ្វើកសិកម្មចម្រុះឱ្យអស់លទ្ធភាព ហើយក៏ជារបៀបវារៈមួយដ៏សំខាន់ដែលក្រសួងបានណែនាំទៅដល់គ្រប់អង្គភាពជំនាញទាំងអស់ត្រូវយកចិត្តទុកដាក់អនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។

នៅក្នុងឆ្នាំ២០១៧នេះ តាមការកត់សម្គាល់ឃើញថា មកទល់ពេលនេះស្ថានភាពការងារបង្កបង្កើនផលស្រូវរដូវវស្សាបានបញ្ចប់ដោយសម្រេចបានចំនួន ២ ៦៥៧ ៧៦៨ហ.ត ស្មើនឹង១០៦,៤៥% នៃផែនការ ២ ៤៩៦ ៧៩០ហ.ត។ ការប្រើប្រាស់ដោយគ្រឿងយន្តសម្រាប់ផលិតកម្មកសិកម្មគឺ ស្មើនឹង ៩៣,៧៣% ធៀបនឹងការប្រើប្រាស់ដោយគោ-ក្របីមាន ៦,២៧% រីឯការចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀត ជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល ក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង ព្រមទាំងបទល្មើសចលនាសត្វដោយខុសច្បាប់ ការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្មដែលនាំឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងឆ្នាំ២០១៧នេះគឺក្រសួងបានរៀបចំកិច្ចប្រជុំសំខាន់ៗ ការរៀបចំសន្និបាតកសិកម្មទូទាំងប្រទេស ការរៀបចំមច្ឆទិវានិងរុក្ខទិវាតាមប្រពៃណី ការរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីមហាអនុតំបន់ទន្លេមេគង្គ (GMS) ការរៀបចំទិវាស្បៀងអាហារពិភពលោកខួបលើកទី៣៧ ការរៀបចំវេទិកាកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការរៀបចំកិច្ចប្រជុំអន្តរក្រសួងនៃក្រុមការងារផ្នែកស្រូវ-អង្ករ("ក្រុមឈ") នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ការរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេសជាច្រើន រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផងដែរ។ ជាមួយនេះដែរ ច្បាប់ស្តីពីជលផលត្រូវបានធ្វើវិសោធនកម្ម និងប្រកាសដាក់ឱ្យប្រើប្រាស់ជាស្ថាពរហើយ។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងឆ្នាំ២០១៧នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះរដូវវស្សាឆ្នាំ២០១៧

#### ១.១ ផលិតកម្មដំណាំស្រូវ

ការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាឆ្នាំ២០១៧ ត្រូវបានបញ្ចប់ជាស្ថាពរហើយដែលមានទិន្នន័យលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ២ ៩៤៥ ៣៦១ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ១៨៤ ៦៥២ហ.ត និងដោយគ្រឿងយន្តកសិកម្មមានចំនួន ២ ៧៦០ ៧០៩ហ.ត តិចជាងឆ្នាំមុន ៥៥ ៧២៤ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ៤១ ៩៣៣ហ.ត តិចជាងឆ្នាំមុន ៨ ៦៨៦ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ២ ៦៥៧ ៧៦៨ហ.ត ស្មើនឹង១០៦,៤៥% នៃផែនការ ២ ៤៩៦ ៧៩០ហ.ត លើសឆ្នាំមុនចំនួន ៥៨ ១៨២ហ.ត។

### ១.២ ល្បឿនការងារប្រមូលផលស្រូវ

ការងារប្រមូលផលស្រូវរដូវវស្សារហូតមកដល់ពេលនេះ សម្រេចបានចំនួន ២ ៣៨២ ៩២៩ហ.ត លើផ្ទៃដីអនុវត្ត សរុប ២ ៦៥៧ ៧៦៨ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៧ ១៨៤ ៩០៦តោន លើសឆ្នាំមុនចំនួន ៣២៧ ០៩៩ តោន។ ទិន្នផលគិតជាមធ្យម ៣,០១៥តោន/ហ.ត លើសឆ្នាំមុន ៥០គ.ក្រ/ហ.ត។

### ១.៣ ផលិតកម្មដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៧-២០១៨

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវប្រាំងគិតត្រឹមថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ មានលទ្ធិផលដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៣៤៨ ៣៤២ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៧ ៥៩៣ហ.ត និងដោយគ្រឿងយន្តមានចំនួន ៣៤០ ៧៤៩ហ.ត តិចជាងឆ្នាំមុនចំនួន ២០ ៩៦២ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ១៥០ហ.ត តិចជាងឆ្នាំមុនចំនួន ២៩ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ៣៣១ ៨៦៣ហ.ត ស្មើនឹង ៧៤,៨១% នៃផែនការ ៤៤៣ ៦០០ហ.ត លើសឆ្នាំមុនចំនួន ២៤ ៣៦២ហ.ត។

### ១.៤ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៧

-ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន ៣៥ ៤១៥ហ.ត ស្មើនឹង៣៧,៨៩% នៃផែនការ ៩៣ ៤៦៥ហ.ត លើសឆ្នាំមុន ចំនួន ៩ ០០៨ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៤ ៦៥៨ហ.ត ស្មើនឹង៣០,៦៨% នៃផែនការ ១៥ ១៨៥ហ.ត តិចជាង ឆ្នាំមុនចំនួន ១ ២៧៤ហ.ត។

### ១.៥ ការនាំចេញអង្ករ

ក្នុងខែធ្នូ ឆ្នាំ២០១៧នេះ ការនាំអង្ករចេញតាមរយៈច្រកចេញ-ចូលតែមួយគឺមានបរិមាណសរុបចំនួន ៧៣ ៤៤២តោន ដែលមានការកើនឡើងចំនួន ១០ ៩៨៧តោន (+១៧,៦០%) ធៀបនឹងបរិមាណនាំចេញក្នុងខែធ្នូ ឆ្នាំ២០១៦។ សរុប រយៈពេល១២ខែឆ្នាំ២០១៧ នាំចេញបានចំនួន ៦៣៥ ៦៧៩តោន (១២ខែឆ្នាំ២០១៦នាំចេញបានចំនួន ៥៤២ ១៤៤តោន (+១៧,៣០%)) ទៅកាន់ទិសដៅចំនួន ៦៣ប្រទេស ក្នុងនោះប្រទេសចិនឈរលំដាប់ទី១ (១៩៩ ៨៥៧តោន) ប្រទេស បារាំងឈរលំដាប់ទី២ (៧៧ ៣៦៣តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៣ (៤៤ ០២៣តោន) ប្រទេសម៉ាឡេស៊ីឈរ លំដាប់ទី៤ (៣៨ ៣៦០តោន) ប្រទេសបង់ក្លាដេសឈរលំដាប់ទី៥ (៣១ ៤៧០តោន) ប្រទេសនីដឺឡែនឈរលំដាប់ទី៦ (២៧ ១៧៥តោន) ប្រទេសអង់គ្លេសឈរលំដាប់ទី៧ (២៦ ៧៧៥តោន) ប្រទេសហ្គាបុងឈរលំដាប់ទី៨ (២៤ ៦៧៧ តោន) ប្រទេសប៊ែលហ្សិកឈរលំដាប់ទី៩ (២០ ០៦០តោន) និងប្រទេសឆែកឈរលំដាប់ទី១០ (១៧ ៣៣០តោន)។ បច្ចុប្បន្នការនាំចេញអង្ករមានចំនួន ៨៤ក្រុមហ៊ុន។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| លរ | អង្គភាព | ផ្ទៃដីអាជីកម្ម (ហត) | ផ្ទៃដីចម្ការកៅស៊ូសរុប (ហត) | ផលិតផលអនុវត្តបានប្រចាំឆ្នាំ (តោន) | បញ្ចេញលក់ប្រចាំឆ្នាំ(តោន) |
|---|---|---|---|---|---|
| I.ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៥៨៣ | ៧៧៦ | ៦០០ | ៥៥០ |
| សរុប I | | ៥៨៣ | **៧៧៦** | ៦០០ | ៥៥០ |

| | | | | | |
|---|---|---|---|---|---|
| II. ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុនសុភក្តិនិកា អ៊ិនវេសមេនគ្រុប | ១១ ១២៧ | ១៤ ២៥៩ | ១៧ ៦៤៨ | ១៥ ៩៨៦ |
| ២ | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | ៩៧៤ | ២ ១៣៥ | ១ ៥៣៥ | ១ ៥៣៣ |
| ៣ | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៤ ១៣១ | ៨ ៦៦៧ | ៤ ២០៤ | ៣ ៧៨២ |
| ៤ | ក្រុមហ៊ុន ស៊ីហ្វ៊ាប់បើលីមីធីត (រតនគិរី) | ៧៩ | ២ ៦៦៦ | ៦៤៦ | ៣៤៦ |
| ៥ | ក្រុមហ៊ុនស៊ីហ្វ៊ីសេសស(ស្នួល) | ៣ ៨៥៩ | ៤ ៤០៦ | ៣ ៥២៣ | ២ ២៤៤ |
| ៦ | ក្រុមហ៊ុន ឡុង ស្រេង | ៤ ៤០២ | ៥ ៩៣៩ | ៤ ៨៨៦ | ៤ ៦៨៤ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣ ៣២៧ | ៥ ៩២៤ | ២ ៨៨៣ | ២ ៨៤៥ |
| ៨ | ក្រុមហ៊ុនអានម៉ាឌីគ្រុប (ពាមជាំង រោងសំហេក) | ១ ៨៨២ | ៣ ១២៤ | ១ ៤៤៥ | ១ ៤១០ |
| ៩ | ក្រុមហ៊ុនក្រែក(ខេមបូឌា)ខូអិលធីឌី | ៤ ១៣៥ | ៤ ៧៩៨ | ៥ ៤១៥ | ៥ ២៥២ |
| សរុបII | | ៣៣ ៩១៤ | ៥១ ៩១៩ | ៤២ ១៨៦ | ៣៨ ០៨២ |
| III. ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៣៥ ២២៩ | ២២៧ ៥៣២ | ៤០ ៨០០ | ៤២ ៥០០ |
| ១២ | ក្រុមហ៊ុនចម្ការកៅស៊ូគ្រួសារ | ១០០ ៥០៤ | ១៥៦ ១១២ | ១០៩ ៧០០ | ១០៧ ៧០០ |
| សរុប III | | ១៣៥ ៧៣៣ | ៣៨៣ ៦៤៤ | ១៥០ ៥០០ | ១៥០ ២០០ |
| សរុប I + II + III | | ១៧០ ២៣០ | ៤៣៦ ៣៣៩ | ១៩៣ ២៨៦ | ១៨៨ ៨៣២ |

**២.១.១ ផលិតកម្ម**

ក្នុងរយៈពេល១២ខែ ឆ្នាំ២០១៧មានចំនួន ១៩៣ ២៨៦តោន បានកើនឡើងចំនួន ៤៨ ០៨៧ តោន ស្មើនឹង ៣៣% បើធៀបរយៈពេលដូចគ្នាទៅនឹងឆ្នាំមុន។

**២.១.២ បរិមាណបញ្ចេញលក់ជ័រកៅស៊ូ**

បរិមាណបញ្ចេញលក់ជ័រកៅស៊ូក្នុងរយៈពេល១២ខែ ឆ្នាំ២០១៧មានចំនួន ១៨៨ ៨៣២តោន បានកើនឡើងចំនួន ៤៣ ៧៣២តោន ស្មើនឹង៣០% បើធៀបរយៈពេលដូចគ្នាទៅនឹងឆ្នាំមុន។

តម្លៃលក់ជ័រកៅស៊ូមធ្យមក្នុងរយៈពេល១២ខែគឺ ១ ៥៨៦ដុល្លារ/តោន បានកើនឡើង ៣០៣ដុល្លារ/តោន ស្មើនឹង ២៤% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

តម្លៃលក់មធ្យមប្រចាំខែគឺ ១ ៤២២ដុល្លារ/តោន បានថយចុះចំនួន ៣០ដុល្លារ/តោន ស្មើនឹង២,០៤% ធៀបនឹងខែវិច្ឆិកា ឆ្នាំ២០១៧ និងបានថយចុះចំនួន ៣០១ដុល្លារ/តោន ស្មើនឹង ១៧% ធៀបនឹងខែធ្នូ ឆ្នាំ២០១៦។

**២.១.២ ការប្រមូលចំណូលថវិកា**

ក្នុងរយៈពេល១២ខែ ឆ្នាំ២០១៧នេះ ការប្រមូលចំណូលថវិកាសរុបបានចំនួន ១ ៤៦៦ ០៤២ ០០៩រៀល ថ្លៃឈ្នួលដីរបស់ក្រុមហ៊ុនចម្ការកៅស៊ូចម្ការអណ្តូង មេមត់ ជុប ក្រែក ក្រុមហ៊ុននីហាវ៉ែណអាហាវ៉ែណកៅស៊ូ (និងប្រាក់ពិន័យក្រុមហ៊ុនចម្ការកៅស៊ូស្នួល ចម្ការអណ្តូង ពាមជាំង ឆ្នាំ២០១៦)។ ដោយឡែកក្នុងខែធ្នូនេះការប្រមូលចំណូលបានចំនួន ២៦៧ ៩០៧ ៣៣៥រៀល។

**២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

- បានចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្តង់ដារជាតិនៅវិទ្យាស្ថានស្តង់ដារកម្ពុជា
- បានចូលរួមកិច្ចប្រជុំស្តីពីអភិក្រមនៃការអនុវត្តលក្ខន្តិកៈគតិយុត្ត ស្តីពីការបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល និងការអនុវត្តនីតិវិធីហិរញ្ញវត្ថុរបស់គ្រឹះស្ថាន
- បានធ្វើតេស្តមន្ទីរពិសោធន៍ក្នុងស្រុកបានចំនួន ០៤លើក ដើម្បីវាយតម្លៃសមត្ថភាពមន្ទីរពិសោធន៍មូលដ្ឋាន និងបានធ្វើតេស្តអន្តរមន្ទីរពិសោធន៍បានចំនួន ០២លើកជាមួយ International Rubber Association (IRA)

- បានចុះត្រួតពិនិត្យតាមបណ្តាមន្ទីរពិសោធន៍និងរោងចក្រកែច្នៃកៅស៊ូ
- បានបើកវគ្គបណ្តុះបណ្តាលដល់កសិករបានចំនួន ០៦វគ្គដែលមានសមាសភាពចូលរួមចំនួន ៣៨២នាក់
- បានវិភាគ DRC តាមមេត្រូឡាក់ តាមការផុតរក TSC និងការវិភាគតាមចម្ការមន្ទីរពិសោធន៍ចំនួន ០៣ដង
- ក្រុមការងារច្បារពូជចុះត្រួតពិនិត្យវាយតម្លៃច្បារពូជកៅស៊ូ នៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម បានចំនួន ០៤ច្បារពូជ
- បានដាំដុះកៅស៊ូឆ្នាំ២០១៧ ចំនួន ១២,៥ហ.ត
- បាញ់ថ្នាំការពារព្យាបាលជំងឺផ្កាកុលាបានចំនួន ០២ដង លើផ្ទៃដីចម្ការចំនួន ១៦២,៥ហ.ត។

## ៣ ផ្នែកកសិ-ឧស្សាហកម្ម

- បានរៀបចំការប្រជុំចែករំលែកបទពិសោធន៍មេរៀនដែលបានរៀនពីប្រទេសជប៉ុន អំពីតម្លៃបន្ថែមផលិតផលកសិកម្មនៅប្រទេសជប៉ុន

- បន្តរៀបចំប្រជុំក្រុមការងារបច្ចេកទេសបាន ២ដង លើច្បាប់ស្តីពីគុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម

- បន្តស្រាវជ្រាវឯកសារពាក់ព័ន្ធនឹងប្រព័ន្ធវិញ្ញាបនបត្រទៅលើត្រី សាច់ បន្លែ ផ្លែឈើ គ្រាប់ធញ្ញជាតិ និងវារីវប្បកម្ម

- បានសហការជាមួយគម្រោង SCCRP រៀបចំសិក្ខាសាលាស្តីពី ការណែនាំសម្រាប់ការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យានៅខេត្តសៀមរាប និងខេត្តបាត់ដំបងមានសមាសភាពចូលរួមចំនួន ៥០នាក់

- បានចូលរួមធ្វើបទបង្ហាញផ្សព្វផ្សាយពីយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យារៀបចំដោយក្រសួងពាណិជ្ជកម្ម និងអង្គការ UNDP

- បានចូលរួមអមដំណើរប្រតិភូប្រទេសហ្វីលីពីន ចុះទស្សនកិច្ចសិក្សាបច្ចេកទេសលើដំណាំម្រេចនៅខេត្តកំពត និងខេត្តត្បូងឃ្មុំ

- បានវិភាគរកវត្តមានកាកសំណល់ Organophosphate and Carbamate លើដំណាំ ខាត់ណាដើម ផ្សិតភ្លៅមាន់ គល់ស្លឹកគ្រៃហាន់រួច និងពោតបារាំង

- បានរៀបចំឧបករណ៍ពាក់ព័ន្ធសម្រាប់ផ្នែកវិភាគគុណភាព និងអាហារូបត្ថម្ភ។

## ៤ ផ្នែកផលិតកម្ម និងបសុព្យាបាល

**៤.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តាខេត្ត និងរាជធានីរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) បន្តចុះអប់រំណែនាំ ផ្សព្វផ្សាយ ការអនុវត្តបច្ចេកទេសល្អប្រសើរក្នុងការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ (គ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វនិងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើស្ទូនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករនិងភ្នាក់ងារសុខភាពសត្វភូមិ ក្រោមកិច្ចសហការបន្តជាមួយគម្រោង EU-PGAL។

### ៤.២ ការងារបសុព្យាបាល

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** ក្នុងឆ្នាំ២០១៧នេះ រាជធានី-ខេត្តចំនួន២២ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ៣៩ ៨៧៩លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យនិងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តទូទាំងប្រទេសបានចំនួន ២៩ករណី ដោយបានកម្ទេចចោលផលិតផលខូចគុណភាពតាមវិធានបសុពេទ្យសរុបចំនួន ១ ៣២៥គ.ក្រ និងផាកពិន័យចំនួន ១៦លានរៀល ព្រមទាំងបានណែនាំដល់អាជីវករដែលដឹកជញ្ជូនសត្វរស់ឲ្យប្រតិបត្តិជីវសុវត្ថិភាពពេញលេញដើម្បីការពារការឆ្លងរាលដាលនៃជំងឺផ្សេងៗ។

- **ការងារសុខភាពសាធារណៈ៖** ចុះត្រួតពិនិត្យជាប្រចាំលើទីតាំងស្នើសុំបង្កើតនិងបន្តសុពលភាពសត្តឃាតដ្ឋានប្រភេទ «ក» និង«ខ»តាមបណ្តារាជធានី-ខេត្ត។ រហូតមកទល់ពេលនេះសត្តឃាតដ្ឋានទទួលបានគោលការណ៍អនុវត្តចំនួន

១៦៨កន្លែង និងបានចុះត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋានឱ្យស្របតាមលក្ខណៈបច្ចេកទេស ដើម្បីសុខុមាលភាពសាធារណៈ។ ជាមួយនេះអង្គភាពជំនាញបានសហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចុះអន្តរាគមន៍សង្គ្រោះសត្វ និងចាក់ថ្នាំបង្ការជំងឺឆ្លងសត្វនៅតាមបណ្តាខេត្ត។

- **ការងារនីតិកម្មនិងវិវាទ៖**

- សម្រេចបានប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យនិងអង្គភាពចំណុះនាយកដ្ឋាននិងវិទ្យាស្ថាននៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ

- សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីកិច្ចសម្របសម្រួលក្នុងការបង្កើតនិងគ្រប់គ្រងសត្តឃាតដ្ឋាន

- បានរៀបចំកែសម្រួលអនុក្រឹត្យលេខ១០៨អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ ឡើងវិញឱ្យស្របតាមច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ

- បានរៀបចំចងក្រងអនុក្រឹត្យនិងប្រកាសមួយចំនួនដើម្បីរៀបចំជាសៀវភៅផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត។

### ៤.៣ ការងារស្រាវជ្រាវ៖

- **ការងារស្រាវជ្រាវបសុព្យាបាល៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺនិងងាប់ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ៤ ៣៧៦វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺជាពិសេសមេរោគជំងឺផ្តាសាយបក្សី ដោយបានរកឃើញជំងឺផ្តាសាយបក្សី$H_5N_1$ នៅលើសត្វមាន់-ទា០៤ករណី នៅខេត្តកំពង់ធំ កំពង់ចាម និងខេត្តស្វាយរៀង។

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោ-ក្របីភ្នំកាម៉ៅមានគោសរុបចំនួន ១២២ក្បាល ក្នុងនោះគោបា ១ក្បាល គោមេប្រាមាន់កាត់ ១៤ក្បាល គោជំទង់ ២៩ក្បាល គោបៅដោះ ៣៤ក្បាល គោកំផែងសែន ៤៤ក្បាល។ ដោយឡែកនៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុប ២៨៣ក្បាល។ ការបង្កាត់ពូជតាមបែបសិប្បនិម្មិតនិងធម្មជាតិប្រព្រឹត្តទៅជាប្រក្រតីនិងបានផ្សព្វផ្សាយបច្ចេកទេសបន្តទៅដល់កសិករ។

**៤.៤ ការងារផ្សព្វផ្សាយបច្ចេកទេស៖** ចងក្រងឯកសារការងារផលិតកម្មនិងបសុព្យាបាលសម្រាប់ចុះក្នុងទស្សនាវដ្តី រៀបចំកម្មវិធីផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល ជាពិសេសផ្សព្វផ្សាយដល់ប្រជាជនឱ្យយល់ដឹងពីជំងឺផ្តាសាយបក្សី ជំងឺជ្រូកត្រចៀកខៀវ និងជំងឺផ្សេងៗទៀតដែលអាចកើតឡើងជាយថាហេតុ រួមទាំងពង្រឹងយន្តការផ្សព្វផ្សាយតាមរយៈ ភ្នាក់ងារសុខភាពសត្វភូមិ។

## ៥ ផ្នែកព្រៃឈើ

### ៥.១ ការងារព្រៃឈើ

- ស្នើសុំប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន ៥១ សហគមន៍ ដែលមានផ្ទៃដីសរុប ៥៧ ៦៧៩ហ.ត

- បានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍រវាងខណ្ឌរដ្ឋបាលព្រៃឈើ និងគណៈកម្មការគ្រប់គ្រងព្រៃសហគមន៍ព្រៃឈើចំនួន ៤៩កន្លែង មានផ្ទៃដីទំហំ ៣០ ៥៩៣ហ.ត

- បានបើកវគ្គផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង ការគ្រប់គ្រង និងការអនុវត្តលិខិតបទដ្ឋានច្បាប់សហគមន៍ព្រៃឈើ ផលប្រយោជន៍ព្រៃសហគមន៍ និងនីតិវិធីទប់ស្កាត់បទល្មើសព្រៃសហគមន៍ចំនួន ២០វគ្គ ជូនដល់សហគមន៍ព្រៃឈើចំនួន ២០ មានសមាសភាពចូលរួមចំនួន ៨៣៣នាក់

- ចុះតាមដាន និងពិនិត្យការងារសហគមន៍ព្រៃឈើចំនួន ១៣៩កន្លែង

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ៣៤ក្រុមហ៊ុន និងអតិថិជនចំនួន ០៨នាក់ មានឈើហ៊ុបមូលចំនួន ៤៥ ១២៨ម៣ ឈើអារចំនួន ២ ៦៤៧ម៣ ឈើលេខ១ចំនួន ៨ ០០០ម៣ ឈើជ្រុងចំនួន ១១ ១០៣ម៣ កូនក្រឡឹងចំនួន ៧៦៩ម៣ កូនឈើសរុបចំនួន ១ ០១២ ០០០ដើម និងអុសចម្រុះចំនួន ២០២ ៧៥១ស្ទែរ ជ័រទឹកចំនួន ១ ០៣១តោន ឫស្សីចំនួន ៥០៣តោន ជន្លង់ម្រេចចំនួន ១៤ ៨៩៨ដើម ដើមទ្រៀកចំនួន ៤ ៥៥៧សន្លឹក និងពកឆ្នង់ចំនួន ២៣២គ.ក្រ។

## ៥.២ ការងារអនិរក្សសត្វព្រៃ

- បានចុះទប់ស្កាត់ និងបង្ក្រាបការជួញដូរសត្វព្រៃចំនួន ៨លើក ដោយចាប់ឃាត់វត្ថុតាងបទល្មើសមានមងសម្រាប់ចាប់សត្វស្លាបបានចំនួន ៣ខ្សែ អន្ទាក់ចំនួន ៨៣ខ្សែ ដកហូតសត្វក្រកូតរស់ចំនួន ២ក្បាល កាំបិតចំនួន ៦ផ្លែ និងអប់រំណែនាំដល់អ្នកលក់សាច់សត្វព្រៃខុសច្បាប់ចំនួន ៤ ករណី

- អប់រំផ្សព្វផ្សាយដល់ប្រជាជនឲ្យមានការយល់ដឹងពីច្បាប់ស្តីពីព្រៃឈើ ការទប់ស្កាត់ការបរបាញ់ ការជួញដូរសត្វព្រៃ និងសារសំខាន់សត្វព្រៃបានចំនួន ៨ លើក មានសមាសភាពចូលរួមសរុបចំនួន ៤៥០នាក់

- សហការជាមួយនិងអង្គការ WCS ចុះដាក់ម៉ាស៊ីនថតស្វ័យប្រវត្តិចំនួន ៣គ្រឿង ក្នុងឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ឃុំវឌ្ឍន ស្រុកសំបូរ ខេត្តក្រចេះ ជាលទ្ធផលថតបានសត្វក្តាន់ ឈ្លូស ស្ការតូច សំពោចក្រអូប និងអកត្រីតូច។

## ៥.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជសត្វស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- ចុះពិនិត្យសំណើសុំគោលការណ៍នាំចេញសត្វស្វាក្តាមចំនួន ៣ ក្រុមហ៊ុន ទៅក្រៅប្រទេសដែលមានសត្វស្វាក្តាមសរុបចំនួន ៤ ៣១០ក្បាល

- ក្រុមហ៊ុនចំនួន ៦ ដែលមានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមយកកូននាំចេញចំនួន ៧ ទីតាំង ស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ធំ ចំនួន ២ក្រុមហ៊ុន ដែលមានសត្វស្វាក្តាមសរុបចំនួន ៥៥ ៧៣៤ក្បាល ក្នុងនោះកូនកើតក្នុងខែមានចំនួន ១០ ១៣០ក្បាល

- សម្រាប់ឆ្នាំ២០១៧ នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ២ ៩៥៦ក្បាល (បក្សីចំនួន ៤៩ ប្រភេទ ថនិកសត្វ ចំនួន ៤២ ប្រភេទ និងល្មូនចំនួន ១២ ប្រភេទ) សង្គ្រោះសត្វថ្មីចំនួន ១ ៦១៨ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន ៣៦៤ក្បាល ស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃគ្រប់ប្រភេទចំនួន ១ ៥៣៧ក្បាល។ ដោយឡែក គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ៖ ក្រុមល្បាតសហគមន៍ចំនួន ៣០នាក់ បានដើរល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗ ចំនួន ៥រួមមាន នៅអារ៉ែង ឆាយរាប តំបន់ស្ការក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- បានតាមដានក្រពើនៅក្នុងតំបន់អភិរក្សបានជួបប្រទះក្រពើភ្នំផ្ទាល់ចំនួន ១៦ក្បាល ស្លាកស្នាមចំនួន ១៧កន្លែង លាមកចំនួន ៣៨កន្លែង និងបានលែងក្រពើភ្នំចំនួន ៦ក្បាល ទៅក្នុងស្ទឹងកំពង់គាជ័យ ខេត្តកោះកុង

- បានសហការជាមួយអ្នកជំនាញក្រពើពីសហរដ្ឋអាមេរិក ដោយបង្រៀនអំពីវិធីសាស្ត្របច្ចេកទេសចាប់។ បានបញ្ជូនសំណាកឈាមក្រពើស្ងួតចំនួន ៥៥សំណាក ទៅវិភាគDNA ដើម្បីស្វែងរកក្រពើសុទ្ធនៅប្រទេសថៃ

- បានជួសជុលផ្លូវលុបសំបុកមាន់ដែលក្រាលគ្រួសក្រហមប្រវែង ១២គ.ម និងកាប់ឆ្ការអនាម័យព្រៃសរុបទំហំ ៣៧ហ.ត ជួសជុលទ្រុងសត្វ និងសាងសង់សំណង់ផ្សេងៗបានទំហំ ៤ ២៧៣ម²។

## ៥.៤ ការងារដាំដើមឈើ

- បានបណ្តុះកូនឈើគ្រប់ប្រភេទចំនួន ៤០៧ ៩៤៨ដើម និងចែកកូនឈើជូនប្រជាពលរដ្ឋចំនួន ៣៣០ ០៧៣ដើម សម្រាប់ដាំនៅទីសាធារណៈ

- ចុះសិក្សា និងស្រាវជ្រាវទីតាំងសម្រាប់ការដាំឈើថ្នាក់ជាតិដោយបង្កើតបានស្ថានីយ និងស្តារព្រៃឈើចំនួន ៥៣កន្លែង ដែលមានផ្ទៃដីសរុប ៤១១ ០២១,០៣៨ហ.ត

- ប្រារព្ធពិធីរុក្ខទិវាថ្នាក់ជាតិនៅក្នុងភូមិក្រាំងក្រូច ឃុំទូលព្រេច ស្រុកអង្គស្នួល ខេត្តកណ្តាល ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា លើផ្ទៃដីទំហំ ១០ហ.ត បានដាំកូនឈើសរុបចំនួន ១០ ៧២៦ដើម ក្នុងនោះមានធ្នង់ចំនួន ៥ ៩២៨ដើម និងគីនីនចំនួន ៤ ៧៩៨ដើម

- បាននិងកំពុងដាំជួស និងថែទាំកូនឈើនៅចម្ការពូជឈើក្នុងស្រុក (ធ្នង់ គ្រញូង គគីរ កកោះ) លើផ្ទៃដីទំហំ ៥០ហ.ត នៅខេត្តកំពង់ធំ ហើយក្រៅពីនេះនៅមានការបេះប្រមូលគ្រាប់ពូជ បេង កកោះ ធ្នង់ បានចំនួន ១ ០០០គ.ក្រ

- បានដាំដុះកូនឈើប្រភេទគ្រញូង ធ្នង់ គគីរ ឈើទាល និងអាកាស្យាជាមួយនឹងដំណាំកសិកម្មរួមមាន៖ ពោត និងដំឡូងលើផ្ទៃដីទំហំ ១៥ហ.ត ដោយបង្កើតជាឡូតិ៍បង្ហាញកសិ-រុក្ខកម្មនៅខេត្តកំពង់ធំ។

### ៥.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- បានចុះពិនិត្យដល់ទីតាំងជាក់ស្តែងតាមលក្ខណៈបច្ចេកទេស ដើម្បីពិនិត្យសម្រេចចំពោះក្រុមហ៊ុនចំនួន ៣៩ ដែលបានស្នើសុំបន្តសុពលភាពរោងម៉ាស៊ីនអារ-កែច្នៃឈើ និងក្រុមហ៊ុនចំនួន ១៤ ដែលបានស្នើសុំបង្កើតរោងសិប្បកម្មកែច្នៃឈើចំនួន ១៧ កន្លែង

- ក្រុមហ៊ុនចំនួន ១០ បានធ្វើការនាំចេញផលិតផលរានទេវតា និងឈើកែច្នៃទៅក្រៅប្រទេសមានបរិមាណសរុបចំនួន ៩ ០២១ម៣ ជ័រទឹកចំនួន ២៩២តោន និងធ្យូងអាកាស្យាចំនួន ៣៣តោន

- ក្រុមហ៊ុនចំនួន ៤ បានធ្វើការនាំចូលឈើ Plywood Paticle Board Radiata MDFChanfutaUmbila និងWood Panel ពីប្រទេស ចិន កូរ៉េ វៀតណាម ជប៉ុន សហរដ្ឋអាមេរិក នីហ្សេរីយ៉ា ញូហ្ស៊ីលែន ខេមីរ៉ូន និងប្រទេសម៉ូហ្សាំប៊ិក មានបរិមាណសរុបចំនួន ៥ ០២៨ ម៣

- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន ១២ មានបរិមាណឈើកែច្នៃសរុបចំនួន ១១ ៣៣១ម៣ ចំណាំងកម្ទេចឈើចំនួន ៦ ០០០តោន ជ័រទឹកចំនួន ៣៩៦តោន និងផលិតផលធ្យូងអាកាស្យាចំនួន ៦០តោន ព្រមទាំងបានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលផលជូនក្រុមហ៊ុនចំនួន ៤ មានបរិមាណឈើកែច្នៃចំនួន ៥ ៩៧៦ ម៣ ។

### ៥.៦ ការងារចំណូលព្រៃឈើ

- សម្រាប់ឆ្នាំ២០១៧នេះ ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើសរុបចំនួន ២៦ ៥២៨ ៩៨៨ ៧៩៨រៀល និងចំណូលពីសេវាសាធារណៈចំនួន ៨ ៣២១ ៤១៤ ៩៤៣រៀល និង១៧៨ ០០៣,៧១ដុល្លារអាមេរិក។

### ៥.៧ ការងារនីតិកម្មនិងវិវាទ

- សម្រាប់ឆ្នាំ២០១៧នេះ សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃសរុបចំនួន ១ ៤២៨ករណី ដោយពិន័យអន្តរការណ៍ចំនួន ៦៥០ករណី និងបញ្ជូនទៅតុលាការមានចំនួន ៧៧៨ករណី ចំពោះវត្ថុតាង បទល្មើសព្រៃឈើដែលបានចាប់ឃាត់រួមមានឈើមូល-ជ្រុងចំនួន ៤៨០ម៣ ឈើអារចំនួន ២ ៩០២ម៣ គ្រាក់គ្រញូងចំនួន ៦៣ម៣ និង២ ២៤៨គ.ក្រ សត្វព្រៃចម្រុះប្រភេទចំនួន ៤ ១១៥ក្បាល និង២ ៤០៩គ.ក្រ និងអនុផលព្រៃឈើព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត

- បានផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធព្រៃឈើចំនួន ៥៨លើក ដែលមានសមាសភាពចូលរួមសរុបចំនួន ១ ៦៦៧នាក់ ក្នុងនោះមានស្ត្រីចំនួន ៥៣៣នាក់ និងចែកឯកសារពាក់ព័ន្ធចំនួន ៣ ៦៣១ ច្បាប់ នៅក្នុងខេត្តចំនួន ១៧

- ចុះអនុវត្តសារាចរលេខ ០២ស.រ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ របស់រាជរដ្ឋាភិបាលស្តីពីការកាន់កាប់ដីរដ្ឋខុសច្បាប់ ជូនដល់ប្រជាពលរដ្ឋ អាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ និងអង្គភាពពាក់ព័ន្ធបានចំនួន១២លើក មានអ្នកចូលរួមសរុបចំនួន ៦៧នាក់ ក្នុងនោះស្ត្រីចំនួន ៣២នាក់

- បន្តដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើសត្វព្រៃ និងកាប់រានដីព្រៃទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ (Case Tracking System-CTS) ដើម្បីរៀបចំឱ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប។

## ៦ ផ្នែកជលផល

### ៦.១ អាជីវកម្មនេសាទ

#### ៦.១.១ នេសាទទឹកសាប

- ជាយត្រី អនុវត្តបានចំនួន ១៦ ៦២៥តោន ស្មើនឹង១៣៨,៥៤% នៃផែនការ ១២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ២ ៦៧៥តោន

- នេសាទគ្រួសារក្នុងដែននេសាទ អនុវត្តបានចំនួន ៣៥២ ៤៧០តោន ស្មើនឹង១០២,៤៦% នៃផែនការ ៣៤៤ ០០០ តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ ថយចុះចំនួន ៣ ៨៧០តោន

- នេសាទគ្រួសារតាមវាលស្រែ អនុវត្តបានចំនួន ១៥៨ ៧០០តោន ស្មើនឹង១១០,២១% នៃផែនការ ១៤៤ ០០០ តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ១១ ៩០០តោន។

#### ៦.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ១២១ ០២៥តោន ស្មើនឹង១១០,០២% នៃផែនការ ១១០ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៤២៥តោន។

### ៦.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្កា អនុវត្តបានចំនួន ២០៧ ៨៤៣តោន ស្មើនឹង១២០,០៥% នៃផែនការ ១៧២ ៨០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៣៤ ៩៤៣តោន

- ការចិញ្ចឹមក្រពើ អនុវត្តបានចំនួន ៣១០ ០០០ក្បាល ស្មើនឹង១២៤,០០% នៃផែនការ ២៥០ ០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៣ ០០០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ២០៥ ០០០ ០០០កូន ស្មើនឹង១០២,៥០% នៃផែនការ ២០០ ០០០ ០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួនប្រមាណ ១១ ០០០ ០០០កូន។

### ៦.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទ អនុវត្តបានចំនួន ៧២ ០០០តោន ស្មើនឹង៨៧,៨០% នៃផែនការ ៨២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ១ ៨០០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ១០ ៦០០តោន ស្មើនឹង១៣២,៥០% នៃផែនការ ៨ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៧៥តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ៥៧ ០០០ ០០០លីត្រ ស្មើនឹង១១៤,០០% នៃផែនការ ៥០ ០០០ ០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ២ ០០០ ០០០លីត្រ។

### ៦.៤ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់អនុវត្តបានចំនួន ៨ ៥០០តោន ស្មើនឹង៥៦,៦៧% នៃផែនការ ១៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ ថយចុះចំនួន ៦០០តោន

- ផលនេសាទកែច្នៃអនុវត្តបានចំនួន ៤ ៥០០តោន ស្មើនឹង៩០,០០% នៃផែនការ ៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ ថយចុះចំនួន ៧០០តោន។

### ៦.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សម្រាប់ឆ្នាំ២០១៧នេះ សំណុំរឿងបទល្មើសជលផលមានចំនួន ៣ ៩២៥ករណី ប្រៀបធៀបក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ២៧៥ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ៣ ៨៨៨ករណី និងសមុទ្រចំនួន ៣៧ករណី

- ចុះរុះរើនិងបំផ្លាញចោលវត្ថុតាងបទល្មើសជលផលរួមមាន៖ របាំងស្បៃមុងនិងសាច់អួនប្រវែង ១ ៥៥៩ ២០៤ម៉ែត្រ បង្គោល/ចម្រឹងចំនួន ៧៧៣ ១៣២ដើម លូស្បៃមុងនិងសាច់អួនចំនួន ២២ ២៣៨មាត់ របាំងព្រួលឫស្សីប្រវែង ៥ ៩៨២ ម៉ែត្រ សម្រាស់ទំហំ ៣៧ ៧២០ម៉ែត្រក្រឡា ឧបករណ៍ឆក់ត្រីចំនួន ៤៥០គ្រឿង និងលែងត្រីចម្រុះចូលក្នុងបឹងធម្មជាតិចំនួន ៨១ ៦៨០គ.ក្រ និងពិន័យអន្តរការណ៍ចំនួន ១០៦ករណី ស្មើនឹងទឹកប្រាក់ចំនួន ២៣០ ៦៦៥ ០០០រៀល

- បានផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធចំនួន ២៩៨វគ្គ ដោយមានអ្នកចូលរួមចំនួន ៩ ៦៥៨នាក់

- បានធ្វើវិសោធនកម្មច្បាប់ស្តីពីជលផលដែលត្រូវបានស្ថាប័ននីតិប្រតិបត្តិ និងនីតិប្បញ្ញត្តិអនុម័ត និងប្រកាសដាក់ឱ្យប្រើប្រាស់ជាស្ថាពរហើយ

- បានរៀបចំទិវាមច្ឆជាតិដែលប្រព្រឹត្តទៅនៅថ្ងៃទី០១ កក្កដា នៅទំនប់សេកសក ស្រុករតនមណ្ឌល ខេត្តបាត់ដំបងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី** តំណាងដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

### ៦.៦ ការប្រមូលចំណូល

- ចំណូលពីវិស័យជលផលក្នុងឆ្នាំ២០១៧ ចំនួន ២ ៩៩៨ ៧៤៦ ៦៨៤រៀល ស្មើនឹង៩៩,៩៦% នៃផែនការ ៣ ០០០ ០០០ ០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៦០២ ៣៥៦ ៦០៥រៀល។

## ៧ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ក្នុងឆ្នាំ២០១៧នេះ តាមរយៈគេហទំព័រ http://www.cardi.org.kh និង http://crkb.org.kh: នេះមានអ្នកបើកស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មរបស់វិទ្យាស្ថានសរុបចំនួន ៥៧៤ ៩១៨នាក់ ហើយគិតជាមធ្យមមានប្រមាណ ១ ៥៧៥នាក់/ថ្ងៃ

- បានធ្វើទិវាស្រែបង្ហាញចំនួន ១៥លើក ដែលមានកសិករចូលរួមចំនួន ៦៨២នាក់ ប្រជុំក្រុមកសិករចំនួន ០២ លើក ដែលមានកសិករចូលរួមចំនួន ១៣នាក់ និងបើកវគ្គបណ្តុះបណ្តាលកសិករចំនួន ៨៤លើក ដែលមានកសិករចូលរួម

ចំនួន ២ ៤២៥នាក់។ បានចែកគ្រាប់ពូជស្រូវជូនដល់កសិករចំនួន ៥៨៣គ្រួសារ នៅខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ ត្បូងឃ្មុំ កែប និងកំពត ដែលក្នុងមួយគ្រួសារចំនួន ៥គ.ក្រ សរុបចំនួន ២ ៩១៥គ.ក្រ

- បានវិភាគសំណាកដីចំនួន១៨២សំណាក លើ pH, EC, OC, OM, N, P, K, Ca, Mg, Na និងវាយនភាពដី

- បានអនុវត្តលើការវិភាគគុណភាពអង្ករលើលក្ខណៈរូបសាស្ត្រដោយប្រើម៉ាស៊ីនS21 អាមីឡូសជាតុ សីតុណ្ហភាពចម្អិន និង Gel consistency សរុបបានចំនួន៤៩សំណាក

- បានបន្តការដាំពង្រីកនិងអភិរក្សដំណាំចំនួន៥ប្រភេទ រួមមានចេក ដំឡូងឈើ ដំឡូងជ្វា ដំឡូងបារាំង និងពពួកផ្កាមួយចំនួន

- បានបន្តបញ្ចូលទិន្នន័យពិសោធន៍ឆ្នាំ២០១៧ ព្រមទាំងបញ្ចូលទិន្នន័យ និងធ្វើការវិភាគជាបណ្តើរៗរាល់ពិសោធន៍ដែលចប់សព្វគ្រប់

- បានបន្តអភិរក្សពូជស្រូវ ចេក និងដំណាំផ្សេងៗនៅក្នុងវិទ្យាស្ថាន

- បានបន្តធ្វើបសិដ្ឋកម្មពូជស្រូវ ដែលបានបញ្ចេញដើម្បីឲ្យកាន់តែមានភាពធន់ទ្រាំទៅនឹងភាពរាំងស្ងួត ទឹកជំនន់ កត្តាចង្រៃ និងជំងឺនឹងបន្តការអភិរក្សពូជស្រូវធន់ជាតិប្រៃ និងពូជស្រូវវារដែលមានលទ្ធភាពវារឡើងតាមទឹកខ្លាំង

- បានបន្តអភិវឌ្ឍពូជស្រូវ និងដំណាំចម្ការឲ្យមានអាយុកាលខ្លីនិងធន់ទៅនឹងកំដៅ

- បានបន្តការស្រាវជ្រាវលើការគ្រប់គ្រងជីជាតិដី និងដំណាំ

- បានបន្តការស្រាវជ្រាវលើបច្ចេកទេសមុន និងក្រោយការប្រមូលផល ព្រមទាំងវិធានការគ្រប់គ្រងកត្តាចង្រៃ។

## ៨ ផ្នែកនីតិកម្មកសិកម្ម

### ៨.១ ការងារអាជីវកម្មសម្ភារកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាសម្ភារកសិកម្មបានចំនួន ២០៥ក្រុមហ៊ុន សរុបចំនួន ២ ០២២មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលសម្ភារកសិកម្មចំនួន ២៥០ក្រុមហ៊ុន
- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៨៤ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៦៩ក្រុមហ៊ុន។

### ៨.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគសារធាតុលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំចុះបញ្ជិកាចំនួន ៨៦ក្រុមហ៊ុនសរុបចំនួន ៤៧៣សំណាក។

### ៨.៣ ការងារបណ្តុះបណ្តាល អប់រំ និងលើកកម្ពស់ការយល់ដឹង

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពី បទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្មសម្ភារកសិកម្ម។

### ៨.៤ ការងារអនុវត្តច្បាប់

- បានធ្វើប្រតិវេទន៍ដល់ក្រុមហ៊ុនចំនួន ១១១

- ពិន័យអន្តរការណ៍ចំនួន ៦៦ករណី ជាប្រាក់ចំនួន ១១២ ៩០០ ០០០រៀល ពីក្រុមហ៊ុនចំនួន ១៧ អាជីវករលក់ដុំ លក់រាយចំនួន ៤៩ដេប៉ូ។

## ៩ ផ្នែករដ្ឋបាល

- ក្នុងឆ្នាំ២០១៧នេះ បានទទួលលិខិតពីក្រសួង-ស្ថាប័ននានាចំនួន ៣ ៧៤៦ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ៤ ១០៣ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ២ ៣៨០ច្បាប់ និងចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តរដ្ឋបាល

- បញ្ជូនឯកសារនិងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ១១ ៣៨២ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៧១០ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទចំនួន ២៦៥ ច្បាប់

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំ ពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។

## ១០ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៦ ៧០៣នាក់ ក្នុងនោះនារីចំនួន ១ ៥២២នាក់ ស្មើនឹង ២២% រួមមាន៖
  + អង្គភាពថ្នាក់កណ្តាលចំនួន ២ ៧៥១នាក់ ក្នុងនោះនារីចំនួន ៧៨៣នាក់ ស្មើនឹង ២៨%
  + អង្គភាពថ្នាក់ក្រោមជាតិចំនួន ៣ ៩៥២នាក់ ក្នុងនោះនារីចំនួន ៧៣៦នាក់ ស្មើនឹង ១៨%
- ត្រូវបានតែងតាំងដំឡើងឋានៈ និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការ សរុបមានចំនួន៣៨៧នាក់ នារីចំនួន ៩០នាក់)
- បានចេញប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌមានចំនួន ៤២នាក់ក្នុងនោះ បោះបង់ចោលការងារមានចំនួន ១០នាក់ សុំលាឈប់ពីការងារមានចំនួន ១៧នាក់ (ស្រី០៧នាក់) និងមរណភាព មានចំនួន ១៥នាក់ (ស្រី០២នាក់)
- បានចេញប្រកាសផ្ទេរមន្ត្រីរាជការក្រៅក្រសួងមានចំនួន ២៣នាក់ក្នុងនោះ ផ្ទេរចេញមានចំនួន ១៤នាក់ និងផ្ទេរចូលមានចំនួន ០៩នាក់ ផ្ទេរចេញផ្ទៃក្នុងក្រសួងមានចំនួន ១៣០នាក់ ក្នុងនោះ ផ្ទេរចេញចំនួន ៦៦នាក់ ផ្ទេរចូលមានចំនួន ៦៤នាក់
- បានធ្វើលិខិតផ្តល់នីត្យានុកូលភាពជូនមន្ត្រីរាជការចំនួន ៩៨នាក់ (ស្រី១៧នាក់)
- បានចុះបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីរាជការលើកការងាររដ្ឋបាល និងបុគ្គលិកចំនួន០៣តំបន់សមាសភាពចូលរួមចំនួន ១៨១នាក់
- បានចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកការងារមានចំនួន ១២៧នាក់ (ស្រី៦២នាក់) ក្នុងនោះ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំមានចំនួន ៧២នាក់ (ស្រី២១នាក់) ច្បាប់ព្យាបាលជំងឺមានចំនួន ២០នាក់ (ស្រី០៦នាក់) និងច្បាប់លំហែមាតុភាពមានចំនួន ៣៥នាក់
- ការងារបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេសសរុបមានចំនួន ៣ ៥៨៩នាក់ (ស្រី ៩៨៣នាក់)។

## ១១ ការងារសវនកម្មផ្ទៃក្នុង

- ក្នុងឆ្នាំ២០១៧ បានចុះធ្វើសវនកម្មបានចំនួន ៤៦សវនដ្ឋាន ស្មើនឹង១០០% នៃផែនការ និងការអនុវត្តអនុសាសន៍គ្រាមុនរបស់សវនដ្ឋានសម្រេចបានចំនួន ៥០% នៃផែនការចំនួន ៤៦% និងបានរកឃើញលទ្ធផលសវនកម្មនិងផ្តល់អនុសាសន៍សម្រប់សវនដ្ឋានកែលម្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមានចំនួន ៣៦៣អនុសាសន៍ គិតជាមធ្យមមានចំនួន ០៧អនុសាសន៍/០១សវនដ្ឋាន ក្នុងនោះ សវនដ្ឋានចំនួន ២២មានអនុសាសន៍ក្រោមមធ្យម សវនដ្ឋានចំនួន ០៧មានអនុសាសន៍មធ្យម និងសវនដ្ឋានចំនួន ១៧មានអនុសាសន៍លើមធ្យម
- បានចុះធ្វើសវនកម្មនៅវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា សាលាកសិកម្មទាំង០៣ រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល អគ្គនាយកដ្ឋានកសិកម្ម អគ្គនាយកដ្ឋានកៅស៊ូ អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ នាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស នាយកដ្ឋានកិច្ចការរដ្ឋបាល នាយកដ្ឋាននីតិកម្មកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំង២៥ រាជធានី-ខេត្ត
- បានធ្វើផែនការយុទ្ធសាស្ត្រថវិកាកម្មវិធីឆ្នាំ២០១៨-២០២០
- បានរៀបចំបើកវគ្គបណ្តុះបណ្តាលស្តីពី "បច្ចេកទេសសវនកម្មលើគម្រោងឥណទានក្រៅប្រទេស" ដល់មន្ត្រីនាយកដ្ឋានសវនកម្មផ្ទៃក្នុង
- បានរៀបចំកិច្ចប្រជុំជាមួយប្រតិភូសវនកម្មផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីចុះពិនិត្យប្រសិទ្ធភាពលើមុខងារសវនកម្មផ្ទៃក្នុង
- បានបញ្ជូនរបាយការណ៍តាមដាននិងវាយតម្លៃការអនុវត្តថវិកាកម្មវិធីតាមទម្រង់M1 និងរបាយការណ៍សមិទ្ធកម្មតាមដានការអនុវត្តថវិកាកម្មវិធីប្រចាំឆមាសទី១ ឆ្នាំ២០១៧
- បានធ្វើសំណើសុំតែងតាំងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គភាព
- បានធ្វើផែនការវដ្តទេយ្យបុរេប្រទានថវិកាកម្មវិធីឆ្នាំ២០១៨។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានរៀបចំលិខិតទៅ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ស្តីពីរបាយការណ៍លទ្ធផលដំណើរទស្សនកិច្ចទៅកាន់ប្រទេសបែលហ្ស៊ិក និងអាឡឺម៉ង់ របស់ឯកឧត្តម

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទពីថ្ងៃទី១៥-២១ ខែមករា ឆ្នាំ២០១៧ និងសំណើសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ដើម្បីដឹកនាំគណប្រតិភូធ្វើទស្សនកិច្ចផ្លូវការនៅប្រទេសអូស្ត្រាលី កាលពីថ្ងៃទី១៩-២៥ ខែវិច្ឆិកា ឆ្នាំ២០១៧

- បានធ្វើសំណើសុំការអនុញ្ញាតជាគោលការណ៍ជូនឯកឧត្តម ទី សុគន្ធ រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីចូលរួមសន្និសីទលើកទី៤០ នៃអង្គការ FAO នៅទីក្រុងរ៉ូម ប្រទេសអ៊ីតាលី និងគោលការណ៍ជូនឯកឧត្តម ណៅ ធួក រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីចូលរួមកិច្ចប្រជុំលើកផែនការថ្នាក់តំបន់រៀបចំគម្រោង គំនិតផ្តួចផ្តើមធ្វើផ្លូវចរាចរណ៍ត្រីនៅតំបន់មេគង្គក្រោម នៅទីក្រុងបាងកក ប្រទេសថៃ

- បានរៀបចំលិខិតសំណើសុំការអនុញ្ញាត ដើម្បីដឹកនាំគណៈប្រតិភូចូលរួមក្នុងវេទិការលើកទី១ ស្តីពីជលផលនិងការតាំងពិព័រណ៍ចំណីអាហារសមុទ្រពិភពលោកនៅទីក្រុង Saint Petersburg នៃសហព័ន្ធរុស្ស៊ី

- បន្តអនុស្សរណៈនៃការយោគយល់គ្នារវាងរដ្ឋាភិបាលកម្ពុជា និងអង្គការអន្តរជាតិស្ម័គ្រចិត្តជប៉ុន JVC អង្គការ Dana Asia អង្គការ Oxfam Australia អង្គការ ADDA អង្គការ ADG និងអង្គការ RECOFTC

- បានផ្តល់យោបល់លើសេចក្តីព្រាងផែនការការងារនៃកិច្ចសហប្រតិបត្តិការអាស៊ានបូកបីឆ្នាំ២០១៨-២០២២

- បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពី Joint Formulation of the Plan on Modern Agricultural Development with the Ministry of Agriculture of the People's Republic of China

- បានធ្វើសំណើសុំសិទ្ធិប្រទានដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី (AFoCO) នៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េ

- បានរៀបចំលិខិតទៅក្រសួងផែនការ ករណីសំណើផ្តល់យោបល់លើសេចក្តីព្រាងនៃក្របខ័ណ្ឌព្រមព្រៀងរួមនៃការតភ្ជាប់សេដ្ឋកិច្ចរវាងប្រទេសកម្ពុជា-វៀតណាម

- បានរៀបចំលិខិតទៅស្ថានទូតរុស្ស៊ីស្តីពី Questionary Regarding Access to the Cambodian Market of Meat/Meat Products and Cereal Product

- បានរៀបចំលិខិតទៅស្ថានទូតចិនស្តីពី Goods List of Household Biogas Degester Equipment

- បានធ្វើសេចក្តីព្រាងជូនភាគីរុស្ស៊ីលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពី លទ្ធកម្មនៃផលិតកម្មកសិកម្មរវាងកម្ពុជា រុស្ស៊ី។

## ១៣ មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- បានសហការលើការងារសិក្សា និងប្រមូលទិន្នន័យពីអង្គភាពជំនាញនីមួយៗ ដើម្បីជាដំណើរការក្នុងការបង្កើត និងធ្វើបច្ចុប្បន្នភាពគេហទំព័រ

- បានចុះទៅប្រមូលទិន្នន័យបឋម និងបង្កើតគេហទំព័រជូនដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសរុបចំនួន ២៥មន្ទីររាជធានី-ខេត្ត

- បានចុះទៅប្រគល់-ទទួលគេហទំព័រដែលបានបង្កើតរួចហើយជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រមទាំងបានបណ្តុះបណ្តាលមន្ត្រីថ្នាក់ខេត្តឲ្យមានលទ្ធភាពក្នុងការគ្រប់គ្រង និងប្រើប្រាស់គេហទំព័រមន្ទីរខេត្ត បានចំនួន ១៣ខេត្ត

- បានបញ្ចប់ការធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរួចរាល់

- បានបង្កើតប្រព័ន្ធគ្រប់គ្រងអ៊ីនធើណេតសម្រាប់ការិយាល័យនីមួយៗ

- បានតំឡើង ព្រីនធ័រមេ (Printer Server) ងាយស្រួលក្នុងការ Print ឯកសារសម្រាប់ការិយាល័យរៀងៗខ្លួន

- រៀបចំតំឡើងបន្ទប់ម៉ាស៊ីនមេ (Server Room) ឲ្យមានលក្ខណៈដាច់ដោយឡែក ដើម្បីសុវត្ថិភាពម៉ាស៊ីនមេ (Server) និងឧបករណ៍ដែលពាក់ព័ន្ធ

- តំឡើងប្រព័ន្ធម៉ាស៊ីនមេ (Server) មានដូចជា: ម៉ាស៊ីនមេ (Server) Switch Router UPS

- ម៉ាស៊ីនមេ (Server) បានតំឡើងកម្មវិធី File Cloud Server ដែលមានសមត្ថភាពផ្ទុកទិន្នន័យ ៥00GBហើយកម្មវិធី File Cloud Server នេះត្រូវបានដាក់ឈ្មោះថា AIDOC Cloud Server ដែលមានតួនាទីសំខាន់ក្នុងការរក្សាទុកឯកសារលើបណ្តាញម៉ាស៊ីនមេ (Server) ហើយអាចឲ្យអ្នកប្រើប្រាស់ទាញយក ឬចែករំលែកទិន្នន័យបាន គ្រប់ពេលវេលា និងនៅទីកន្លែងណាក៏បានតាមរយៈកុំព្យូទ័រ ឬស្មាតហ្វូនដែលមានភ្ជាប់ប្រព័ន្ធអ៊ីនធើណេត

- បានកំណត់វិសាលភាពសម្រាប់គណនេយ្យតាមបណ្តាខេត្ត ដោយមិនអាចប៉ះពាល់ខេត្តដទៃបានឡើយ

- បានកែប្រែផ្ទាំងបញ្ចូលទិន្នផលដំណាំកសិកម្មទៅជាទម្រង់ថ្មីដែលផ្តល់ភាពងាយស្រួលសម្រាប់អ្នកប្រើប្រាស់ និងមានភាពរហ័សជាងមុន

- បានបញ្ចូលទិន្នន័យដែលប្រមូលបានសម្រាប់យកមកសាកល្បងដើម្បីបង្កើតប្រព័ន្ធ។

## ១៤ ការងារអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១៤.១ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំសិក្សា២០១៦-២០១៧ សរុបមានចំនួន ៣ ៦៣៨នាក់ (ស្រី១ ១៨៦នាក់) ចែកចេញជា ១០មហាវិទ្យាល័យគឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញារង និងថ្នាក់បរិញ្ញាវិទ្យាសាស្រ្ត និងសាលាក្រោយឧត្តមសម្រាប់ការបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិត

- បានប្រារព្ធពិធីចែកសញ្ញាបត្រ ជូនដល់និស្សិតជ័យលាភីថ្នាក់បរិញ្ញារង បរិញ្ញា បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិត សរុបចំនួន ២១៦៨នាក់

- បានដឹកនាំនិស្សិតចូលរួមវេទិកាពិភាក្សាអំពីកិច្ចសហប្រតិបតិបត្តិការកម្ពុជាចិនផ្លូវមួយខ្សែក្រវ៉ាត់មួយនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា បានដឹកនាំនិស្សិតចូលរួមមិទ្ទិញទិវាប្រឆាំងការជួញដូរមនុស្ស

- បានជួបពិភាក្សាស្តីពីកិច្ចសហប្រតិបត្តិការលើការងារអប់រំជាមួយប្រតិភូសាកលវិទ្យាល័យ ហ៊ីរ៉ូស៊ីម៉ា នៃប្រទេសជប៉ុន

- បានជួបពិភាក្សានិងចុះអនុស្សរណៈយោគយល់ជាមួយសភាវិទ្យាសាស្ត្រកសិកម្មនិងព្រៃឈើខេត្ត Hebei នៃសាធារណរដ្ឋប្រជាមានិតចិន

- បានទទួលអ្នកជំនាញការកូរ៉េពីអង្គការ KOICA ចំនួនមួយរូបជំនាញគ្រឿងយន្តកសិកម្មមកបម្រើការងារក្នុងមហាវិទ្យាល័យវិស្វកម្មកសិកម្ម និងបានទទួលរថយន្ត ១២កៅអីចំនួន ១គ្រឿងពីអង្គការ KOPIA។

### ១៤.២ សាលាជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៦-២០១៧ សរុបចំនួន ៥១៣នាក់ (ស្ត្រី ១៨១នាក់) ក្នុងនោះនិស្សិតថ្នាក់បរិញ្ញាបត្រចំនួន ៤១៣នាក់(ស្ត្រី ១៤២នាក់) និងនិស្សិតថ្នាក់បរិញ្ញាបត្ររងចំនួន ១០០នាក់(ស្ត្រី ៣៩នាក់) លើជំនាញ៖ កសិកម្ម ជលផល ព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ សាកវប្បកម្ម ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិ-ឧស្សាហកម្ម និងសុរិយោដី

- បានសហការជាមួយកូរ៉េលើការស្រាវជ្រាវផ្នែកបណ្តុះជាលិកាផ្កា
- បានដឹកនាំនិស្សិតដាំដំណាំបន្លែ និងចិញ្ចឹមត្រី
- បានបើកវគ្គបណ្តុះបណ្តាលបន្តជំនាញវិទ្យាសាស្រ្ត និងវេជ្ជសាស្ត្រសត្វឆ្នាំទី៣
- បានចុះអនុស្សរណៈយោគយល់គ្នាជាមួយ Hirushima University ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការរួមគ្នា
- បន្តសហការជាមួយ Vitrosyste ក្រុមហ៊ុនប្រទេសកូរ៉េ ដើម្បីជំរុញការស្រាវជ្រាវផ្នែកបណ្តុះជាលិកា
- បន្តសហការជាមួយ Cambodia-Japan Research Center for Agriculture ដើម្បីជំរុញការស្រាវជ្រាវដំណាំកសិកម្ម
- បានដឹកនាំនិស្សិតដាំដំណាំបន្លែ ចិញ្ចឹមត្រី និងមាន់ពិសោធន៍។

### ១៤.៣ សាលាជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០១៧-២០១៨ សរុបមានចំនួន ៥៨៧នាក់(ស្ត្រី ២៦១នាក់) រួមមាន៖ និស្សិតអាហារូបករណ៍សរុប ៤៧៣នាក់ (ស្ត្រី ២៣០នាក់) និស្សិតសិក្សាបង់ថ្លៃចំនួន ១១៤នាក់ (ស្ត្រី ៣១នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- បានរៀបចំពិសោធបន្សុទ្ធពូជពោតដំណើប
- បានចុះសិក្សាលើដំណាំម្រេច
- បានពិសោធប្រៀបធៀបការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា
- បានចាប់ផ្តើមពិសោធចិញ្ចឹមដង្កូវនាងព្រៃ និងបានផ្តល់ពូជដង្កូវនាងព្រៃទៅកសិករចិញ្ចឹមចំនួន ១០គ្រួសារ
- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហម
- បានបណ្តុះបណ្តាលមន្ត្រីលើការងារគ្រប់គ្រងមន្ទីរពិសោធន៍ និងវិភាគបាក់តេរី

- បានពិសោធន៍សាកល្បងដីលើដំណាំបន្លែ។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលដំណាំស្រូវវស្សាបានបញ្ចប់ហើយដោយសម្រេចបានចំនួន ២ ៦៥៧ ៧៦៨ហ.ត ស្មើនឹង១០៦,៤៥% នៃផែនការ ២ ៤៩៦ ៧៩០ហ.ត។ ជាមួយនឹងការខិតខំប្រមូលផលដំណាំរដូវវស្សាយ៉ាងសស្រាក់សស្រាំរបស់ប្រជាកសិករ ក្រសួងក៏បានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើយន្តការ និងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗតាមការចាំបាច់ និងសហការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការតាមដានវាយតម្លៃអំពីការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ ក៏ដូចជាការណែនាំឱ្យរក្សាទឹកទុកសម្រាប់ការងារដាំដុះដំណាំរដូវប្រាំងនាពេលខាងមុខនេះ ព្រមទាំងផ្សព្វផ្សាយអំពីការចូលរួមទប់ស្កាត់ភ្លើងឆេះស្រូវ និងឆេះព្រៃជាយថាហេតុផងដែរ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ដូចជាការជំរុញឱ្យចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វ បទល្មើសព្រៃឈើនិងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងក៏បានបន្តជំរុញគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ ព្រមទាំងពង្រឹងស្មារតីទទួលខុសត្រូវក្នុងការឆ្លើយតបឱ្យបានទាន់ពេលវេលាលើមូលបញ្ហាទាំងឡាយដែលបានលើកឡើងក្នុងសារព័ត៌មាននិងបណ្តាញសង្គមផ្សេងៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រ គោលនយោបាយតាមអនុវិស័យសំខាន់ៗ និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអន្តរស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ជារួម ដោយមានការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយនូវរាល់ការលំបាកផ្សេងៗប្រកបដោយមោទកភាពពិតមែន ទោះនៅមានបញ្ហាប្រឈមខ្លះៗក៏ដោយ។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ :

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវរដូវប្រាំង និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណនិងគុណភាពតាមផែនការកំណត់ក្នុងឆ្នាំ២០១៧-២០១៨ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំរួមផ្សំផ្សេងទៀតដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឱ្យបានច្រើនដើម្បីជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ និងកាត់បន្ថយការប្រើប្រាស់សារធាតុគីមី

- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្មសម្រាប់ការងារបង្កបង្កើនផលរដូវវស្សានេះ និងការរៀបចំកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម ដើម្បីពិនិត្យអំពីវឌ្ឍនភាព បញ្ហាប្រឈម និងការលើកទិសដៅអនុវត្តបន្ត

- បន្តណែនាំដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់សហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះធ្វើអន្តរាគមន៍ ដើម្បីស្វែងរកដំណោះស្រាយទប់ស្កាត់ការធ្លាក់ចុះថ្លៃកសិផលផ្សេងៗជាយថាហេតុ ការងារសម្របសម្រួលថ្នាក់តំបន់ និងថ្នាក់ខេត្ត ដើម្បីជួយដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការងារស្រូវអង្ករនៅមូលដ្ឋានក៏ដូចជាទីផ្សារកសិផលផ្សេងៗទៀតផងដែរ

- យកចិត្តទុកដាក់តិតគូរផ្សព្វផ្សាយអំពីការប្រើប្រាស់ជីកសិកម្ម ថ្នាំកសិកម្ម និងសារធាតុគីមីផ្សេងៗទៅលើផលិតផលកសិកម្មដែលនាំឲ្យប៉ះពាល់សុខុមាលភាពសាធារណៈ ការនាំចេញកសិផលទៅក្រៅប្រទេស និងលើកកម្ពស់ផលិតកម្មកសិកម្មសរីរាង្គ

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទ និងរោងចក្រកែច្នៃកៅស៊ូ

- បន្តជំរុញឲ្យអង្គភាពជំនាញចុះធ្វើការអប់រំផ្សព្វផ្សាយបច្ចេកទេសដល់កសិករដាំកៅស៊ូឲ្យបានទូលំទូលាយ ធ្វើការវិភាគសេដ្ឋកិច្ចក៏ដូចជាការបញ្ជ្រាបអំពីតម្លៃកៅស៊ូនៅលើទីផ្សារក្នុងកាលៈទេសៈបច្ចុប្បន្ននេះផងដែរ។

**២ ផ្នែកផលិតកម្មនិងបសុព្យាបាល** :

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទរួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- បន្តរិះរកគ្រប់មធ្យោបាយដើម្បីចូលរួមដោះស្រាយនូវរាល់បញ្ហាប្រឈមទាំងឡាយដែលបានលើកឡើងក្នុងក្របខ័ណ្ឌនៃកិច្ចប្រជុំក្រុមការងារកសិកម្ម និងកសិ-ឧស្សាហកម្ម

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី-ខេត្ត និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឱ្យបានទូលំទូលាយ ជាពិសេសការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមតំបន់ដែលខ្សត់ទឹក

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស ព្រមទាំងជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកគ្រុនខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- បន្តចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី-ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានការបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឱ្យបានសមស្របតាមនីតិវិធី

- បន្តពង្រឹងកិច្ចសហការក្នុងក្របខ័ណ្ឌត្រួតពិនិត្យអនាម័យសត្វ និងផលិតកម្មសត្វក្នុងក្របខ័ណ្ឌទ្វេភាគី តំបន់ និងអន្តរជាតិ ព្រមទាំងចូលរួមក្នុងការប្រឹងប្រែងរៀបចំកិច្ចព្រមព្រៀងទទួលស្គាល់ជំនាញបសុព្យាបាលនៅក្នុងក្របខ័ណ្ឌ ASEAN ដើម្បីសម្រួលដល់ការធ្វើសមាហរណកម្ម ជំនាញបសុព្យាបាលក្នុងចំណោមប្រទេសសមាជិក ASEAN។

**៣ ផ្នែកព្រៃឈើ** :

- បន្តជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ និងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើជាតិ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឱ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និង

ភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរិលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើសំខាន់ៗ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយក្រសួង ស្ថាប័ន សមត្ថកិច្ចជំនាញ សហគមន៍ព្រៃឈើ និងភាគីពាក់-ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាព និងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាព រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ព្រមទាំងការចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃផងដែរ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជាលេខ០១ និង០២ របស់រាជរដ្ឋាភិបាល និងចូលរួមអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព។

**៤ ផ្នែកជលផល**:

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តស្រាវជ្រាវដកហូត និងបោះបង្គោលដីព្រៃលិចទឹកដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ព្រមទាំងគិតគូអំពីមធ្យោបាយសង្គ្រោះធនធានមច្ឆជាតិនៅពេលឡើងកម្តៅខ្លាំងបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៨ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី កង្កែប បង្កាក្ដាម ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការគ្រប់គ្រងលើការចិញ្ចឹមត្រីរ៉ស់ ត្រីឆ្តោឱ្យបានសមស្របតាមវិធានបច្ចេកទេស ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ** :

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម ដើម្បីសុខុមាលភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជីកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- ធ្វើការកែលម្អសេវាសាធារណៈច្រកចេញចូលតែមួយរបស់អង្គភាពពាក់ព័ន្ធក្រោមឱវាទប្រកបដោយតម្លាភាពនិងទាន់ពេលវេលា ការផ្ទេរមុខងារទៅថ្នាក់ក្រោមជាតិតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយ ព្រមទាំងការបញ្ចូលសកម្មភាពយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់ៗតាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស

- បន្តសហការរៀបចំច្បាប់ផ្សេងៗទៀត លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងក្របខ័ណ្ឌកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់តាមបែបវិមជ្ឈការនិងវិសហមជ្ឈការនៅតាមអង្គភាពក្រោមឱវាទតាមការចាំបាច់ និងលំដាប់អាទិភាព

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា ហើយក៏ជាយន្តការមួយ រួមចំណែកអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាពីកសិកម្មបែបវិបុលវប្បកម្មមានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្មមានផលិតភាពខ្ពស់ ការធ្វើកសិកម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលធាតុអាកាស ស្តង់ដារ ពិសេសការបង្កើនផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម៕

ថ្ងៃ សុក្រ ៣កើត ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**